00172130

**Declassified to Public**
**06 September 2012**

លេខ/ No: D25/1/7

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 19 / 03 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

សំណុំរឿងព្រហ្មទណ្ឌ
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 001/18-07-2007-ECCC/OCIJ**

# សេចក្តីសម្រេចទទួលស្គាល់មេធាវី
# Lawyer's Recognition Decision
# Décision d'accréditation d'avocat

ORIGINAL DOCUMENT RECEIVED ON 18-03-2008 AT 16h00 PM BY CHEA Kosal, court officer.

យើង **យូ ប៊ុនឡេង** និង Marcel Lemonde សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ២៣ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច**

បានឃើញលិខិតចាត់តាំងរបស់លោកស្រី **ឈិនណារី** លោក **ប៊ូម៉េង** និង លោក **ជុំមុី** ជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៨ ចំពោះលោកស្រីមេធាវី Silke Studzinsky ដែលទទួលបានការយល់ព្រមត្រឹមត្រូវរួចហើយក្នុងបញ្ជីមេធាវីដែលមានបំណងតំណាងជនរងគ្រោះនៅចំពោះមុខ អ.វ.ត.ក និង ដែលបានស្បថរួចហើយនៅចំពោះមុខសាលាឧទ្ធរណ៍កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០០៨ ជាមេធាវីរបស់ខ្លួន និង ការយល់ព្រមរបស់លោកស្រីមេធាវីនេះ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៨។

## ហេតុដូច្នេះ

ទទួលស្គាល់ លោកស្រីមេធាវី Silke Studzinsky ជាមេធាវីការពារឲ្យដើមបណ្តឹងរដ្ឋប្បវេណីខាងលើ សម្រាប់គោលបំណងនៃកិច្ចស៊ើបសួរនៅចំពោះមុខ អ.វ.ត.ក។

CO-INVESTIGATING JUDGES *E.C.C.C*C.E.T.C* CO-JUGES D'INSTRUCTION

លេខ/ No: D25/1/7

ដោយសារលោកស្រីមេធាវី ត្រូវបានចាត់តាំងជាមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះ សិទ្ធិនិងកាតព្វកិច្ច ខាងក្រោម ត្រូវអនុវត្តចំពោះលោកស្រី៖

- **ការចូលរួមក្នុងកិច្ចការស៊ើបសួររបស់តុលាការ៖** លោកស្រី ត្រូវបានអនុញ្ញាតឲ្យតំណាងកូនក្តីរបស់លោកស្រី នៅក្នុងកំឡុងពេលដែលពួកគេចូលរួមក្នុងនីតិវិធី ដូចមានចែងក្នុងវិធានផ្ទៃក្នុងនៃ អ.វ.ត.ក.។

- **ការពិនិត្យពិគ្រោះសំណុំរឿង៖** លោកស្រី មានសិទ្ធិពិនិត្យមើល និងថតចម្លងឯកសារពីសំណុំរឿងស៊ើបសួរ ច្បាប់ដើមណាដែលកូនក្តីរបស់លោកស្រី ជាដើមបណ្តឹងរដ្ឋប្បវេណី តាមរបៀបថតចម្លងជាក្រដាស ឬ តាមបែបអេឡិចត្រូនិក នៅក្នុងពេលម៉ោងធ្វើការ និងដោយគោរពទៅតាមលក្ខខ័ណ្ឌតម្រូវនៃកិច្ចដំណើរការល្អរបស់អ.វ.ត.ក។ ការពិនិត្យមើលសំណុំរឿងនេះ អាចរៀបចំ ដោយមានជំនួយរបស់អង្គភាពជនរងគ្រោះ ឬមន្ត្រីគ្រប់គ្រងសំណុំរឿង ប៉ុន្តែ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីសមត្ថកិច្ច។ លោកស្រី អាចថតចម្លង ឬស្នើសុំច្បាប់ថតចម្លងឯកសារដែលមាននៅក្នុងសំណុំរឿង តាមចំនួនសមរម្យ និង យកឯកសារទាំងនោះទៅពិភាក្សាជាមួយកូនក្តីរបស់លោកស្រី ប៉ុន្តែ លោកស្រី មិនអាចប្រគល់ឯកសារថតចម្លងទាំងនោះទៅឲ្យកូនក្តីរបស់លោកស្រី ឬ អ្នកដទៃបានឡើយ។

- **ការរក្សាការសម្ងាត់វិជ្ជាជីវៈ និងការសម្ងាត់នៃកិច្ចការតុលាការ៖** តាមរយៈការចូលរួមរបស់កូនក្តីលោកស្រី ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី លោកស្រី និងកូនក្តីរបស់លោកស្រី នឹងអាចពិនិត្យពិគ្រោះព័ត៌មានសម្ងាត់ដែលមាននៅក្នុងសំណុំរឿង។ ប៉ុន្តែ មានតែចៅក្រមនិងព្រះរាជអាជ្ញា នៃអ.វ.ត.ក ប៉ុណ្ណោះ ដែលអាចផ្សព្វផ្សាយព័ត៌មានទាំងនេះជាសាធារណៈបាន។ លោកស្រី ត្រូវចងដោយកាតព្វកិច្ចរក្សាការសម្ងាត់នៃកិច្ចស៊ើបសួររបស់តុលាការ និងក្រមវិជ្ជាជីវៈរបស់លោកស្រី ដោយមិនត្រូវផ្សព្វផ្សាយព័ត៌មានទាំងឡាយដែលលោកស្រីទទួលបានពីការពិនិត្យពិគ្រោះសំណុំរឿងនោះទេ។

- **ការដាក់តំកល់ឯកសារ៖** នៅពេលដែលកូនក្តីរបស់លោកស្រី ត្រូវបានទទួលស្គាល់ជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ រាល់ឯកសារផ្លូវការទាំងអស់ ត្រូវដាក់តំកល់តាមរយៈមន្ត្រីគ្រប់គ្រងសំណុំរឿង ដូចមានកំណត់នៅក្នុងសេចក្តីណែនាំអនុវត្តអំពីការដាក់តំកល់ឯកសារ។ លោកស្រី នឹងទទួលបានការជូនដំណឹងតាមប្រព័ន្ធអេឡិចត្រូនិកអំពីឯកសារដែលបានដាក់បញ្ចូលទៅក្នុងសំណុំរឿង ហេតុនេះ លោកស្រី ត្រូវផ្តល់ជូនអាសយដ្ឋានអ៊ីម៉ែលរបស់លោកស្រីទៅឲ្យក្រឡាបញ្ជីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតសម្រាប់ប្រើក្នុងការទំនាក់ទំនងនេះ។ ការផ្តល់ជូនឯកសារជាក្រដាស អាចធ្វើបានតែក្នុងករណីណាដែលលោកស្រី មិនអាចមើលអ៊ីម៉ែលប៉ុណ្ណោះ។

CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION *E.C.C.C*C.E.T.C*

00172132

លេខ/ No: D25/1/7

វិធាន និងសេចក្តីណែនាំអនុវត្ត ទាក់ទងនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី អាចពិនិត្យពិគ្រោះ និងថតចម្លងបាន តាមរយៈគេហទំព័ររបស់អង្គភាពជនរងគ្រោះ (http://www.eccc.gov.kh/)។ ប្រសិនបើ លោកស្រីត្រូវការការណែនាំបន្ថែមទាក់ទិននឹងការធ្វើជាតំណាងកូនក្តីរបស់លោកស្រី នៅក្នុងដំណើរការនីតិវិធីរបស់អ.វ.ត.ក សូមធ្វើទំនាក់ទំនងជាមួយនឹងអង្គភាពជនរងគ្រោះ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**

**Co-Juges d'instruction**

MARCEL Lemonde　　យូ ប៊ុនឡេង

